# ខ្លឹមសារសង្ខេបអត្ថបទ

**ការចោទប្រកាន់ដោយទុច្ចរិត (malicious prosecution),** John L. Diamond and et al., Understanding Torts, 5th ed., 2013, pp.349-355

**១**. ការចោទប្រកាន់ដោយទុច្ចរិត (MP) ការផ្ដើមនីតិវិធីស៊ីវិល (malicious institution of civil proceedings: MI) និងការបំពាននីតិវិធី អាចនាំឲ្យមានការទទួលខុសត្រូវលើអំពើអនីត្យានុកូល។ ទីនេះជាការចាប់ផ្ដើម គេគួរកត់សំគាល់ថា ការដាក់ពន្ធនាគារខុស (false imprisonment) មិនមែនជាការចោទប្រកាន់ដោយទុច្ចរិតទេ។ ដោយសារ ក្រោយពីមានការចោទប្រកាន់ ដំណើរការនីតិវិធីមានភាពត្រឹមត្រូវ នាំទៅរកការសម្រេចទោស និងដាក់ពន្ធនាគារ ដែលត្រឹមត្រូវតាមច្បាប់ និងនីតិវិធី។ MP និង MI មានធាតុផ្សំដូចគ្នា៖ ១. មានការផ្ដួចផ្ដើម ឬបន្តនីតិវិធីព្រហ្មទណ្ឌ ឬស៊ីវិល ប្រឆាំងនឹងជនជាប់ចោទ។ ២. ការបញ្ចប់នីតិវិធី ផ្ដល់ប្រយោជន៍ដល់ជនជាប់ចោទ។ ៣. អវត្តមាននូវមូលដ្ឋានរឹងមាំ (probable cause) សម្រាប់ការចោទប្រកាន់ ឬនីតិវិធីស៊ីវិល។ ៤. អ្នកចោទប្រកាន់មានគោលបំណងមិនសមរម្យ និងទី៥. ជនជាប់ចោទទទួលរងនូវការខូចខាត។

**២**.សម្រាប់ទី១ ចុងចម្លើយទទួលខុសត្រូវក្នុងការផ្ដួចផ្ដើមនីតិវិធី ក៏ប៉ុន្តែការគ្រាន់តែផ្ដល់សក្ខីកម្មខុសប្រឆាំងនឹងដើមចោទ មិនគ្រប់គ្រាន់សម្រាប់កិច្ចចោទប្រកាន់ដោយទុច្ចរិតទេ រីឯចំណុចទី២. មានន័យថា អ្នកដែលគេចោទ ត្រូវបានសម្រេចឲ្យរួចខ្លួន។ ទី៣. វាមិនមានមូលដ្ឋានសមស្របដែលចុងចម្លើយនឹងមានទោស។ នេះក្នុងន័យថា អ្នកចោទប្រកាន់ ត្រូវជឿថានឹងមានពិរុទ្ធភាព ឬការទទួលខុសត្រូវរបស់ជនជាប់ចោទ បន្ថែមពីលើមូលដ្ឋានមានហេតុផលនេះ។ ជាចុងក្រោយ វាទាមទារឲ្យដើមចោទ បង្ហាញថាអ្នកចោទមានចេតនាទុច្ចរិត តែក្រោយមក ជាទូទៅ វាទាមទារនូវគោលបំណងមិនសមស្រប (improper purpose) ក្នុងន័យថា បុគ្គលណាមួយមិនគិតថាគាត់មានទោស ឬមានការទទួលខុសត្រូវ។ ការខូចខាត ត្រូវបានបង្ហាញដោយដើមបណ្ដឹង។ រដ្ឋខ្លះ អនុលោមតាមវិធានអង់គ្លេស (English Rule) ក្នុងន័យថា លុះត្រាមានការខូចខាតជាពិសេស ដូចជាការដកយកបុគ្គល។ ទោះបីជា

យ៉ាងណាក្តី ក្នុងពេលបច្ចុប្បន្ន ប្រភេទនៃការខូចខាត ត្រូវបានពង្រីក រួមបញ្ចូលផងដែរ នូវការខូចខាតដល់កិត្តិយស។

**៣.** បញ្ហាបំពាននីតិវិធី ក៏អាចពាក់ព័ន្ធនឹងកាទទួលខុសត្រូវលើអំពើអនីត្យានុកូលផងដែរ។ គេអាចប្តឹងបានប្រឆាំងនឹងនីតិវិធីមានវិការៈណាមួយដោយមិនចាំបាច់រង់ចាំលទ្ធផលនៃបណ្តឹងស៊ីវិលទេ។

ពាក់ព័ន្ធការប្តឹងនេះ បញ្ហាអភ័យឯកសិទ្ធិ អាចនឹងត្រូវបានលើកឡើង។ រដ្ឋអាជ្ញា ចៅក្រម មន្ត្រីសាធារណៈ និងរដ្ឋាភិបាល ដែលប្រើប្រាស់ពួកគេ ជាទូទៅ មានអភ័យឯកសិទ្ធិ ចំពោះសេចក្តីសម្រេចជាឆន្ទានុសិទ្ធិ ពីការចោទប្រកាន់។ ក៏ប៉ុន្តែ គេអាចប្តឹងប្រឆាំងបុគ្គលផ្សេង ដែលបង្កើតភស្តុតាងនាំឲ្យមានការចោទប្រកាន់។

**ពាក្យគន្លឹះ៖** មូលដ្ឋានរឹងមាំ, ការបំពាននីតិវិធី, អភ័យឯកសិទ្ធិ។